ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

សំណុំរឿងរដ្ឋប្បវេណី
លេខ : ១២៩
ចុះថ្ងៃទី ០៧ខែមេសាឆ្នាំ ២០០៩
សាលដីកា
លេខ : ១៣ "ផ"
ចុះថ្ងៃទី ០៩ ខែមករាឆ្នាំ ២០១៤

# សាលដីកា

## តាងនាមប្រជារាស្ត្រខ្មែរ

## តុលាការកំពូល

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នាសវនាការជាសាធារណៈនៅថ្ងៃទី ០៩ ខែ មករា ឆ្នាំ ២០១៤។

### សមាសភាពក្រុមប្រឹក្សាជំនុំជំរះ

១-ឯកឧត្តម [redacted] ជាប្រធាន
២-លោក ជាចៅក្រម
៣-លោក ជាចៅក្រម
៤-លោក ជាចៅក្រម
៥-លោក ជាចៅក្រម

### ក្រឡាបញ្ជី

លោកស្រី [redacted]

### តំណាងមហាអយ្យការ

លោក [redacted] ជាព្រះរាជអាជ្ញា

**ដើមចោទៈ**លោក [redacted] ឧន់ (ម្ចាស់បណ្តឹងសាទុក្ខ) អាយុ ៥៩ឆ្នាំ ជាតិខ្មែរ ទីលំនៅសព្វថ្ងៃភូមិថ្នស ឃុំគោកពោធិ៍ ស្រុកបូរីជលសារ ខេត្តតាកែវ។

**មេធាវី** ៈលោក [redacted] តំណាងដោយអាណត្តិ

**ចុងចម្លើយៈ**អ្នកស្រី [redacted] ស្រេន (ម្ចាស់បណ្តឹងសាទុក្ខ) អាយុ ៥៤ឆ្នាំ ជាតិខ្មែរ ទីលំនៅសព្វថ្ងៃភូមិថ្នស ឃុំគោកពោធិ៍ ស្រុកបូរីជលសារ ខេត្តតាកែវ។

**មេធាវី** ៈលោកស្រី [redacted] តំណាងដោយអាណត្តិ

**អំពីវិវាទៈ**-ប្តឹងលែងលះប្រពន្ធ និងបែងចែកទ្រព្យសម្បត្តិរួម



Scanned with CamScanner

## អំពីអង្គហេតុនិង ចំណុចវិវាទៈ

### ក-អំពីអង្គហេតុជាមូលហេតុនៃការទាមទារ:

តាមពាក្យបណ្តឹងចុះថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០០៧ របស់ឈ្មោះ [redacted] នន់ ប្តីចង់លែងលះប្រពន្ធ និង បែងចែកទ្រព្យសម្បត្តិរួមដោយសំអាងហេតុថា ខ្លួនបានរៀបអាពាហ៍ពិពាហ៍ស្របច្បាប់ជាមួយឈ្មោះ [redacted] ស្រេន កាលពីឆ្នាំ ១៩៨៨ ហើយមានកូន ៤នាក់ គឺទី ១ ឈ្មោះ [redacted] សុខា , ទី ២ ឈ្មោះ [redacted] ចន្ទ ,ទី ៣ ឈ្មោះ [redacted] សុភារិទ្ធ ,ទី ៤ ឈ្មោះ [redacted] សុមានិត ពេលនោះមានភ្លើងឆេះផ្ទះអស់នៅសល់ដីមួយប្លង់(ប្លង់ផ្ទះ) មានទំហំ ៧ម គុណ ៣០ម ក្នុងអំឡុងពេលនោះគ្រួសារខ្លួនមានរឿងវិវាទបែកគ្នាមួយរយៈ ទើបបងប្អូនញាតិមិត្តផ្សះផ្សាជាគ្រួសារឡើងវិញនៅឆ្នាំ ១៩៩៦ តែកូនក្នុងបន្ទុកឈ្មោះ [redacted] សុខា និង ឈ្មោះ [redacted] ចន្ទ មានគ្រួសាររៀងខ្លួនហើយ។ ចាប់ពីឆ្នាំ ១៩៩៦ ដល់បច្ចុប្បន្នខ្លួននិងប្រពន្ធព្រមទាំងកូនពីរនាក់រស់នៅជាមួយគ្នាហើយ ទ្រព្យដែលរកបានជាមួយគ្នាគឺដីស្រែ១១,៥ហិកតា ដីប្លង់ផ្ទះមួយកន្លែងទំហំ ១០ម គុណ ៧២មផ្ទះចំនួន៣ តែឈ្មោះ [redacted] ស្រេន លក់ផ្ទះមួយតម្លៃ ៤.០០០.០០០រៀល និង ឥវ៉ាន់ និងគ្រឿងទេសតម្លៃ ៧.០០០ដុល្លា ម៉ូតូមួយគ្រឿងតម្លៃ ៦៥០ ដុល្លា មាសពីរជី។

**បានឃើញសាលក្រមរដ្ឋប្បវេណីលេខ ២១"ក" ចុះថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០០៨ របស់សាលាដំបូងខេត្តតាកែវ សំរេច :**

១-ទទួលស្គាល់បណ្តឹងទាមទាររបស់ដើមចោទឈ្មោះ [redacted] នន់ ចុះថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០០៧ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ និង គតិច្បាប់។

២-ទទួលស្គាល់លិខិតបញ្ជាក់អាពាហ៍ពិពាហ៍លេខ ៩៣៥.០៧គ.៣ ចុះថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ២០០៧ របស់មេឃុំគោកពោធិ៍ ស្រុកបូរីជលសារ ខេត្តតាកែវ ទុកជាត្រឹមត្រូវតាមច្បាប់។

៣-អោយឈ្មោះ [redacted] នន់ (ប្តី) និង [redacted] អ៊ុន ស្រេន(ប្រពន្ធ) បញ្ឈប់ការរស់នៅបែបអនីតិសង្វាសនឹងគ្នាចាប់ពីពេលនេះតទៅ ដោយដាក់កំហុសខាងប្តីតាមមាត្រា ៣៩ ចំណុចទី ៥ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារ។

៤-ទ្រព្យសម្បត្តិរួមមាន :

-ផ្ទះលក់គ្រឿងសំណង់ ០១កន្លែង ដីសម្រាប់សង់លំនៅដ្ឋាន ០១កន្លែង ស្ថិតនៅជាប់ផ្សារថ្មស ឃុំគោកពោធិ៍ និង ដីស្រែប្រាំង ០៣ហិកតា ប្រគល់អោយនាង [redacted] ស្រេន ជាអ្នកគ្រប់គ្រង។

-ដីទំហំ ១០ម គុណ ៦៥ម (មានកូនផ្ទះមួយជាប់ប្រឡាយ ០១ មុខស្ថានីយ៍បូមទឹកថ្មស) ផ្ទះមួយនៅ

មុខស្ថានីយ៍បូមទឹកឃុំគោកពោធិ៍ និង ដីស្រែប្រាំងចំនួន ០៣ហិកតា ប្រគល់អោយឈ្មោះ [redacted] ទន់ ជាអ្នកគ្រប់គ្រង។

៥-រឹបអូសប្រាក់ប្រដាប់ក្តីចំនួន ៧.០០០រៀល ដែលដើមចោទបានបង់ទុករួចហើយ ។

៦-សាលក្រមនេះជំនុំជំរះ និង ប្រកាសជាសាធារណៈ ចំពោះមុខដើមចោទ កំបាំងមុខចុងចម្លើយ តែទុកដូចជាចំពោះមុខ បើកផ្លូវប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

*សាលក្រមនេះត្រូវបានឈ្មោះ [redacted] ស្រេន ប្តឹងឧទ្ធរណ៍តាមបណ្តឹងចុះថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០០៨ លើសាលក្រមទាំងមូល ។*

**បានឃើញសាលដីការដ្ឋប្បវេណីលេខ១៦"ញ" ចុះថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០០៩ របស់សាលាឧទ្ធរណ៍**

**សំរេច :**

១-ទទួលបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០០៨ របស់ឈ្មោះ [redacted] ស្រេន ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ។

២-តម្កល់សាលក្រមរដ្ឋប្បវេណីលេខ ២១"ក" ចុះថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០០៨ របស់សាលាដំបូងខេត្តតាកែវ ទុកជាបានការ លើកលែងតែចំណុចទី-៤ នៃសាលក្រមត្រូវបដិសេធចោល និង សំរេចជាថ្មីដូចខាងក្រោម :

ក/ប្រគល់ដីសង់លំនៅដ្ឋានទំហំ ១០ម គុណ ៦៥ម ផ្ទះលក់គ្រឿងសាងសង់មួយដែលស្ថិតនៅលើទំនប់សាធារណៈ និង ដីស្រែចំនួន ០៣ហិកតា អោយទៅឈ្មោះ [redacted] ស្រេន កាន់កាប់គ្រប់គ្រងនៅពេលសាលដីកានេះចូលជាស្ថាពរ ។

ខ/ប្រគល់ផ្ទះមួយជាប់ប្រឡាយមុខស្ថានីយ៍បូមទឹក និងដីស្រែ ០៣ហិកតា អោយទៅដើមចោទឈ្មោះ សាន់ ទន់ កាន់កាប់គ្រប់គ្រងនៅពេលសាលដីកានេះចូលជាស្ថាពរ ។

៣-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ដើមចោទ ។

៤-សាលដីកានេះ ប្រកាសជាសាធារណៈនៅថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០០៩ ទុកសិទ្ធិអោយប្តឹងសាទុក្ខរយៈពេល ១ខែ គិតពីថ្ងៃបានទទួលការបញ្ជូនសាលដីកានេះ ។

*សាលដីកានេះត្រូវបានឈ្មោះ [redacted] ទន់ ប្តឹងសាទុក្ខតាមបណ្តឹងលេខ ១០៩ ចុះថ្ងៃទី ១១ ខែ មីនាឆ្នាំ ២០០៩ ត្រង់ចំណុចការបែងចែកទ្រព្យសម្បត្តិរួម ។*

*សាលដីកានេះត្រូវបានឈ្មោះ [redacted] ស្រេន ប្តឹងសាទុក្ខតាមបណ្តឹងលេខ ១៣៣ ចុះថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០០៩ ត្រង់ចំណុចទី II (ខ) ទាំងអស់ ។*

<u>ខ-អំពីសេចក្តីថ្លែងការណ៍របស់គូភាគី:</u>

ឈ្មោះ [redacted] ទន់ ធ្វើសេចក្តីថ្លែងការណ៍ថា : ខ្លួនសុំបែងចែកទ្រព្យសម្បត្តិដែលនៅសេសសល់ជា២



Scanned with CamScanner

ស្មើគ្នា ។ ទ្រព្យរួមមានច្រើន តែបានឯកភាពគ្នាលក់ខ្លះនិងខ្លះទៀតចុងចម្លើយលក់មិនស្មោះត្រង់ ។ ដីអោយទៅកូនខ្លួនមិនទាមទារទេ គឺសុំបែងចែកដីស្រែ ៦ហិកតាជាពីរចំណែក និង សុំចែកដី ១០ម គុណ ៦៥ម ជាពីរចំណែកស្មើគ្នា ។

ក្រឡាបញ្ជីអានសារណាតបរបស់ចុងចម្លើយ

លោក [redacted] មេធាវីតំណាងដោយអាណត្តិអោយដើមចោទធ្វើសេចក្តីថ្លែងការណ៍ថា ៈការសុំអោយដីនៅមុខស្ថានីយ៍ទាំងពីរកន្លែងអោយកូនក្តីខ្លួន គឺផ្ទះទាំងពីរកន្លែងនេះស្ថិតនៅលើប្រឡាយសាធារណៈ ត្រូវរដ្ឋអោយរុះរើចេញ ១កន្លែងហើយ នៅសល់តែផ្ទះលើប្រឡាយបូមទឹកគោកពោធិ៍ដែលមិនដឹងរដ្ឋអោយរុះរើចេញពេលណា ដូច្នេះ បើអោយក៏ដូចជាមិនអោយដែរ ។

ទ្រព្យរួមមាន៥កន្លែង តែពេលនេះខ្លួនសុំអោយក្រុមប្រឹក្សាជំនុំជំរះសំរេចបែងចែកដីពីរកន្លែងគឺ ៖

១-ដីស្រែទំហំ ៦ហិកតាជាពីរចំណែក ហើយខ្លួនសុំយកដី ៣ហិកតា ដែលទិញពីឈ្មោះ [redacted] កាន់

២-ដីទំហំ ១០ម គុណ៦៥ម សុំបែងចែកជាពីរចំណែកស្មើគ្នា ។

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់ចម្លើយរបស់ដើមចោទ, លិខិតបញ្ជាក់អំពីមូលហេតុនៃបណ្តឹងសាទុក្ខរបស់ចុងចម្លើយ និង សេចក្តីថ្លែងហេតុរបស់មេធាវីគូក្តី

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

-យល់ឃើញថា បណ្តឹងសាទុក្ខលេខ ១០៩ ចុះថ្ងៃទី ១១ ខែ មីនា ឆ្នាំ ២០០៩ របស់ឈ្មោះ [redacted] ឆន់ និង លេខ ១៣៣ ចុះថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០០៩ របស់ឈ្មោះ [redacted] ស្រេន ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា ១៤ នៃច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពសាលាជំរះក្តី និង មាត្រា ២៨៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

-យល់ឃើញថា តាមចម្លើយរបស់ដើមចោទ និង សេចក្តីបញ្ជាក់អំពីមូលហេតុនៃបណ្តឹងសាទុក្ខរបស់ចុងចម្លើយនៅចំពោះមុខសវនាការតុលាការកំពូល គូភាគីបានឯកភាពលែងលះរួចហើយ ។ ចំពោះដីទំហំ ៧ម គុណ ២០ម ដែលបានចែកអោយកូនរួចហើយនោះ មិនទាមទារវិញទេ ។



Scanned with CamScanner

-យល់ឃើញថា ផ្ទះលក់គ្រឿងសំណង់ដែលសង់ជាប់ប្រឡាយមុខស្ថានីយ៍បូមទឹក ដែលសាលាឧទ្ធរណ៍បានសំរេចប្រគល់អោយភាគីដើមចោទឈ្មោះ [redacted] ឆន់ កាន់កាប់គ្រប់គ្រងនោះ បច្ចុប្បន្នត្រូវបានរដ្ឋអោយរុះរើចេញហើយ ដោយរដ្ឋដកយកដីនេះវិញ ពីព្រោះដីនេះ ជាដីប្រឡាយសាធារណៈ ។ ចំពោះដីលំនៅដ្ឋានទំហំ ១០ម គុណ ៦៥ម ដែលសាលាឧទ្ធរណ៍សំរេចប្រគល់អោយចុងចម្លើយឈ្មោះ [redacted] ស្រេន ក៏ស្ថិតនៅលើដីទំនប់សាធារណៈដែរ ហើយដើមចោទទាមទារដីនេះទំហំពាក់កណ្តាល ។ ដូច្នេះ ដីលំនៅដ្ឋានដែលនៅសល់មានតែមួយកន្លែងទេ គឺដីទំហំ ១០ម គុណ ៦៥ម ប៉ុណ្ណោះ ដែលជាទ្រព្យរួម គប្បីសាលាឧទ្ធរណ៍ពិចារណាជាថ្មី ។

-យល់ឃើញថា ចំពោះដីស្រែប្រាំងមានចំនួន ២កន្លែង ដែលមួយកន្លែងៗមានទំហំ ៣ហិកតា សរុប ៦ហិកតា ។ សាលាឧទ្ធរណ៍សំរេចបែងចែកអោយ ៣ហិកតាម្នាក់នោះ ជាការត្រឹមត្រូវហើយ ក៏ប៉ុន្តែពុំបានសំរេចអំពីទីតាំងដែលជាហេតុនាំអោយមានការពិបាកក្នុងការអនុវត្តការប្រគល់ ។ ម្យ៉ាងទៀត ភាគីដើមចោទបានសំណូមពរសុំយកដីស្រែប្រាំងដែលនៅជិតដីស្រែកូនរបស់គាត់ ។

-យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ ១៦"ញ" ចុះថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០០៩ របស់សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្តីមកនេះត្រឹមត្រូវតាមគតិច្បាប់ខ្លះ ខុសខ្លះ ។

**ហេតុដូចនេះ**

**ស ម្រ េ ច**

**ទ ិ និ ច្ឆ័ យ ស េ ច ក្តី**

១-ទទួលបណ្តឹងសាទុក្ខលេខ ១០៩ ចុះថ្ងៃទី ១១ ខែ មីនា ឆ្នាំ ២០០៩ របស់ឈ្មោះ [redacted] ឆន់ ជាដើមចោទ និង បណ្តឹងសាទុក្ខលេខ ១៣៣ ចុះថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០០៩ របស់ឈ្មោះ [redacted] ស្រេន ជាចុងចម្លើយ ។

២-តម្កល់សាលដីការដ្ឋប្បវេណីលេខ ១៦"ញ" ចុះថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០០៩ របស់សាលាឧទ្ធរណ៍ទុកជាបានការ លើកលែងតែចំណុចទី ២ "ក" និង "ខ" នៃសាលដីការបស់សាលាឧទ្ធរណ៍ស្តីពីការបែងចែកទ្រព្យសម្បត្តិរួម ត្រូវបដិសេធចោល ។

៣-បញ្ជូនសំណុំរឿងរដ្ឋប្បវេណីលេខ ១២៥ ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០៩ របស់តុលាការកំពូលទៅសាលាឧទ្ធរណ៍ ដើម្បីជំនុំជំរះជាថ្មីឡើងវិញ លើចំណុចបែងចែកទ្រព្យសម្បត្តិរួម ។

៤-ប្រាក់ប្រដាប់ក្តីជាន់តុលាការកំពូលជាបន្ទុករបស់ គូក្តី ។



Scanned with CamScanner

៥-សាលដីកានេះជំនុំជំរះជាសាធារណៈ នៅថ្ងៃទី ០៩ ខែ មករា ឆ្នាំ ២០១៤ និង ប្រកាសជាសាធារណៈ នៅថ្ងៃទី ១៦ ខែ មករា ឆ្នាំ ២០១៤។

| | | |
|---|---|---|
| ឯកឧត្តម | [redacted] | ប្រធាន |
| លោក | | ចៅក្រម |
| លោក | | ចៅក្រម |
| លោក | | ចៅក្រម |
| លោក | | ចៅក្រម |
| លោកស្រី | | ក្រឡាបញ្ជី |

---

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម។

ភ្នំពេញ ,ថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០១៤

ក្រឡាបញ្ជី

[redacted]

បានឃើញ

ភ្នំពេញ ,ថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០១៤

ប្រធាន

៣០៤



304